# ពិធីផ្សំសម្ពង្ស

១-ឆ្នាំជូត និង ឆ្នាំជូត សម្បត្តិជាអ្នកជួញ , ឆ្នាំជូត និងឆ្លូវ សម្បត្តិរាជគ្រូ, ឆ្នាំជូត និងខាល សម្បត្តិស្រីលក់ទា , ឆ្នាំជូត និងថោះ សម្បត្តិមហាសេដ្ឋី , ឆ្នាំជូត និងរោង សម្បត្តិអ្នកដើរទូក , ឆ្នាំជូត និងម្សាញ់ សម្បត្តិអ្នកលក់ត្រី , ឆ្នាំជូត និងមមី សម្បត្តិនាយពល , ឆ្នាំជូត និងមមែ សម្បត្តិទេព្តា , ឆ្នាំជូត និងវក សម្បត្តិអ្នកលក់ចេញ , ឆ្នាំជូត និងរកា សម្បត្តិមេជាង , ឆ្នាំជូត និងច សម្បត្តិនាយក្រុម , ឆ្នាំជូត និងកុរ សម្បត្តិនាហ្មឺន ។

២-ឆ្នាំឆ្លូវ និង ឆ្លូវ សម្បត្តិមហាសេដ្ឋី , ឆ្នាំឆ្លូវ និង ខាល សម្បត្តិព្រះរាជទាន , ឆ្នាំឆ្លូវ និង ថោះ សម្បត្តិអ្នកយាមឃ្លាំង , ឆ្នាំឆ្លូវ និង រោង សម្បត្តិអ្នកម្ទាង , ឆ្នាំឆ្លូវ និង ម្សាញ់ សម្បត្តិឧកញ៉ា ,ឆ្នាំឆ្លូវ និង មមី សម្បត្តិមេការ , ឆ្នាំឆ្លូវ និង មមែ សម្បត្តិកុម្ម៉ៃ , ឆ្នាំឆ្លូវ និង វក សម្បត្តិអ្នកដើរទូត , ឆ្នាំឆ្លូវ និង រកា សម្បត្តិនាយក្រុម , ឆ្នាំឆ្លូវ និង ច សម្បត្តិអ្នកមានបុណ្យ , ឆ្នាំឆ្លូវ និងកុរ សម្បត្តិស្តេចមារ ។

៣-ឆ្នាំខាល និងខាល សម្បត្តិទាហាន , ឆ្នាំខាល និងថោះ សម្បត្តិឈ្មួញសំពៅ, ឆ្នាំខាល និងរោង សម្បត្តិនាយសំពៅ , ឆ្នាំខាល និងម្សាញ់ សម្បត្តិជាងមាស , ឆ្នាំខាល និងមមី សម្បត្តិរាជគ្រូ , ឆ្នាំខាល និងមមែ សម្បត្តិអ្នកដើរទូក , ឆ្នាំខាល និងវក សម្បត្តិអ្នកលក់ត្រី , ឆ្នាំខាល និងរកា សម្បត្តិសាធារណ៍ , ឆ្នាំខាល និងច សម្បត្តិនាហ្មឺន , ឆ្នាំខាល និងកុរ សម្បត្តិទេព្តា ។

៤-ឆ្នាំថោះ និងថោះ សម្បត្តិមហាសេដ្ឋី , ឆ្នាំថោះ និងរោង សម្បត្តិអ្នកធ្វើស្រែចំការ , ឆ្នាំរោង និងម្សាញ់ សម្បត្តិព្រហ្មា , ឆ្នាំថោះ និងមមី សម្បត្តិមនុស្សឈ្លោះគ្នា , ឆ្នាំថោះ និងមមែ សម្បត្តិមនុស្សអា ក្រាត , ឆ្នាំថោះ និងវក សម្បត្តិរាជគ្រូ , ឆ្នាំថោះ និងរកា សម្បត្តិមេក្រុម , ឆ្នាំថោះ និងច សម្បត្តិទូក ឈ្នួល , ឆ្នាំថោះ និងកុរ សម្បត្តិខ្មោចទឹក ។

៥-ឆ្នាំរោង និងរោង សម្បត្តិទេព្តា , ឆ្នាំរោង និងម្សាញ់ សម្បត្តិមហាសេដ្ឋី , ឆ្នាំរោង និងមមី សម្បត្តិនាហ្មឺន , ឆ្នាំរោង និងមមែ សម្បត្តិមន្ត្រី , ឆ្នាំរោង និងវក សម្បត្តិព្រះឥន្ទ , ឆ្នាំរោង និងរកា សម្បត្តិអ្នកក្រ , ឆ្នាំរោង និងច សម្បត្តិសេដ្ឋី , ឆ្នាំរោង និងកុរ សម្បត្តិនាយទុន ។

៦-ឆ្នាំម្សាញ់ និងម្សាញ់ សម្បត្តិចូលរោងដំរី , ឆ្នាំម្សាញ់ និងមមី សម្បត្តិសេដ្ឋី , ឆ្នាំម្សាញ់ និង មមែ សម្បត្តិស្តេចផែនដី , ឆ្នាំម្សាញ់ និងវក សម្បត្តិអ្នកជា , ឆ្នាំម្សាញ់ និងរកា សម្បត្តិទេព្តា , ឆ្នាំម្សាញ់ និងច សម្បត្តិស្តេចផែនដី , ឆ្នាំម្សាញ់ និងកុរ សម្បត្តិក្តុម្ពី ។

៧-ឆ្នាំមមី និងមមី សម្បត្តិបរោហិត , ឆ្នាំមមី និងមមែ សម្បត្តិស្តេចផែនដី , ឆ្នាំមមី និងវក សម្បត្តិសេដ្ឋី , ឆ្នាំមមី និងរកា សម្បត្តិសេនាពល, ឆ្នាំមមី និងច និងសម្បត្តិនាយឃ្លាំង , ឆ្នាំមមី និងកុរ សម្បត្តិអ្នកលេង ។

៨-ឆ្នាំមមែ និងមមែ សម្បត្តិមេភូមិ , ឆ្នាំមមែ និងវក សម្បត្តិអ្នកចិញ្ចឹម , ឆ្នាំមមែ និងរកា សម្បត្តិអ្នកលក់ត្រី, ឆ្នាំមមែ និងច សម្បត្តិមហាចោរ, ឆ្នាំមមែ និងកុរ សម្បត្តិនាយសំពៅ ។

៩-ឆ្នាំវក និងវក សម្បត្តិយក្សក្ខិណី , ឆ្នាំវក និងរកា សម្បត្តិអ្នកជា , ឆ្នាំវក និងច សម្បត្តិអ្នក ដើរទូក , ឆ្នាំវក និងកុរ សម្បត្តិសាធារណ៍ ។

១០-ឆ្នាំរកា និងរកា សម្បត្តិអ្នកលក់ចេញ , ឆ្នាំរកា និងច សម្បត្តិនាយរោង , ឆ្នាំរកា និងកុរ សម្បត្តិមនុស្សគេចិញ្ចឹម ។

១១-ឆ្នាំច និងច សម្បត្តិអ្នកត្រួតផ្សារ , ឆ្នាំច និងកុរ សម្បត្តិអ្នកលេង ។

១២-ឆ្នាំកុរ និងកុរ សម្បត្តិព្រាន ។

## តម្រាសមពង្ស

សិទ្ធិការ្យ និងនិយាយអំពីតម្រាសមពង្សដែលហៅថា "វិវាហមង្គលសមពង្ស"ឱ្យបុរស ស្ត្រីរួមមេត្រីស៊ីចុកបុកទំពារជាមួយគ្នា បានបុត្រធីតា មានទ្រព្យភោគា យកសក្តិបរិវារនោះ លោកឱ្យមើលតម្រាសមពង្ស ដូចតទៅនេះ :

## សមពងឆ្នាំកំណើត

ទេវតាប្រុស និងទេវតាស្រី នៅជាមួយគ្នាល្អណាស់ និងមានបុត្រជាទីស្រឡាញ់ ។

ទេវតាប្រុស និងមនុស្សស្រី នៅជាមួយគ្នាជាមធ្យម និងមានបុត្រម្នាក់ ច្រើនកើតវិវាទទាស់ទែង គ្នាព្រាត់ប្រាសទៅហើយទើបជួបគ្នាវិញ ដូចកាលព្រះរាម និងនាង សិតា ។

មនុស្សប្រុស និងទេវតាស្រី នៅរួមជាមួយគ្នាល្អ និងមានកូនចៅជាមួយគ្នា ។ កាលដើមដៃស្រ ឡាញ់គ្នាដល់ចុងក្រោយត្រូវព្រាត់ប្រាសវិនាសចេញ ទីបំផុតទើបជួបជុំគ្នាវិញ ដូចព្រះសុធន និងនាង មនោរា ។

ទេវតាប្រុស និងយក្ខិនី នៅរួមជាមួយគ្នាមធ្យម និងមានបុត្រធីតាច្រើនទាស់ទែងខ្វែងគំនិតប្រឆាំងឫទ្ធីតែរៀងខ្លួន ។

មនុស្សប្រុស និងមនុស្សស្រី នៅរួមគ្នាប្រសើរណាស់ ជាមហាឧត្តមបរមសុខអាយុយឺនយូរ មានបុត្រធីតាកើតលាភផល ។

មនុស្សប្រុស និងយក្ខិនី នៅរួមជាមួយគ្នាជាទីស្រឡាញ់ ពីដើមដៃ ដល់ចុងដៃត្រូវព្រាត់ប្រាសដូច ព្រះរថ និង នាងមេរី ។

យក្ស និងមនុស្សប្រុស នៅរួមគ្នាមិនល្អ និងមានបុត្រស្រឡាញ់គ្នាជាដំបូង ដល់ក្រោយត្រូវព្រាត់ដូចកាលកុម្ព័ណ្ឌ និងនាង កេស្សរមន្ទា ។

យក្ស និងយក្ខិនី នៅរួមគ្នាល្អ មានបុត្រធីតាច្រើន តែកើតវិវាទទាស់ទែងគ្នា ។

<u>សមពង្សអាយុ</u>

សិទ្ធិការ្យ បើចង់ដឹងសមពង្សរបស់បុរស-ស្រ្តីទាំងសងខាងនោះ លោកឱ្យយកអាយុចំនួនច្រើនតាំងខាងលើ ហើយយកចំនួន...

<u>សមពង្សធាតុ</u>

សិទ្ធិការ្យ បើចង់ដឹងសមពង្សធាតុរបស់បុរស-ស្ត្រីទាំងពីរផ្នែក ថាត្រូវគ្នាឬខុសគ្នានោះ លោកឱ្យមើលតាមធាតុកំណើត ដូចតទៅនេះ :

បើប្រុសធាតុទឹក ស្រីធាតុដែក នៅរួមគ្នានឹងបានសុខកាយ សប្បាយចិត្តត្រជាក់ត្រជុំ ។

ប្រុសធាតុទឹក ស្រីធាតុដី នៅរួមគ្នានឹងបានសុខកាយមានសេចក្តីស្រឡាញ់ទៅវិញទៅមកច្រើន។

ប្រុសធាតុទឹក ស្រីធាតុភ្លើង ល្អដែរ ប៉ុន្តែច្រើនបៀតបៀនដល់គ្នា ។

ប្រុសធាតុទឹក ស្រីធាតុដែក ល្អណាស់ និងមានយសសក្តិច្រើន ។

ប្រុសធាតុដី ស្រីធាតុដី ប្រពៃណាស់ និងមានបុត្រធីតានៅរួមគ្នា អាយុយឺនយូរ ។

ប្រុសធាតុដី ស្រីធាតុទឹក នៅរួមគ្នាមួយឆ្នាំទើបបានល្អ មានគេជួយឧបត្ថម្ភ ។

ប្រុសធាតុដី ស្រីធាតុឈើ នៅរួមជាមួយគ្នាមិនសូវល្អឡើយ ។

ប្រុសធាតុដី ស្រីធាតុភ្លើង នឹងបានល្អដល់ចុងដៃ ហើយមានទ្រព្យច្រើន ។

ប្រុសធាតុទឹក ស្រីធាតុដែក នៅជាមួយគ្នាល្អ និងមានកូន៧នាក់ ។

ប្រុសធាតុឈើ ស្រីធាតុឈើ មិនល្អ នៅជាមួយគ្នាមិនកើតលាភផលអ្វីឡើយ ។

ប្រុសធាតុឈើ ស្រីធាតុទឹក ល្អណាស់ នៅរួមគ្នាបានសុខសាន្ត មានភោគទ្រព្យច្រើន ប៉ុន្តែចិញ្ចឹមកូនលំបាក ។

ប្រុសធាតុឈើ ស្រីធាតុដី ស្រឡាញ់គ្នា ប៉ុន្តែត្រូវព្រាត់ប្រាស វិនាសចេញពីគ្នា ។

ប្រុសធាតុឈើ ស្រីធាតុភ្លើង ល្អ និងមានកូនប្រុសមុន តែច្រើនកំព្រា ។

ប្រុសធាតុឈើ ស្រីធាតុដែក មិនល្អ នៅរួមគ្នាមិនបានយូរ ។

ប្រុសធាតុភ្លើង ស្រីធាតុភ្លើង អភ័ព្វ ច្រើនតែព្រួយចិត្ត ។

ប្រុសធាតុភ្លើង ស្រីធាតុទឹក កាលដើមដៃមិនសូវល្អ ដល់ចុងក្រោយទើបល្អ អាយុយឺនយូរ ច្រើនតែឈ្លោះទាស់ទែងគ្នាដោយពាក្យសំដី ។

ប្រុសធាតុភ្លើង ស្រីធាតុដី នៅរួមគ្នា៧ឆ្នាំព្រាត ។

ប្រុសធាតុភ្លើង ស្រីធាតុឈើ មិនល្អ ច្រើនវិវាទទាស់ទែងគ្នា ។

ប្រុសធាតុភ្លើង ស្រីធាតុដែក មិនល្អ ស្វែងរកទ្រព្យសម្បត្តិមិនល្អសោះឡើយ ។

ប្រុសធាតុដែក ស្រីធាតុដែក ល្អណាស់ នៅរួមគ្នានឹងបានត្រជាក់ត្រជុំ ។

ប្រុសធាតុដែក ស្រីធាតុទឹក ល្អណាស់ នៅរួមគ្នានឹងបានត្រជាក់ត្រជុំ សុខកាយសប្បាយចិត្ត ។

ប្រុសធាតុដែក ស្រីធាតុដី នៅជាមួយគ្នាល្អ បរិបូរណ៍ដោយទ្រព្យច្រើន ។

ប្រុសធាតុដែក ស្រីធាតុឈើ នៅរួមជាមួយគ្នាល្អប្រពៃណាស់ និងបានយសសក្តិជាឃុននាង ។

ប្រុសធាតុដែក ស្រីធាតុភ្លើង មិនល្អទេ ច្រើនតែទាស់ទែងជេរបញ្ចោរ វាយដំច្រំធាក់គ្នា ។

ឯធាតុមាសនោះ មិនបាច់ប្រកាន់ថាធាតុណាទេ ចេះតែត្រូវគ្នាទាំងអស់ ហើយល្អប្រសើរគ្រប់ៗ ឆ្នាំ ឥតរើសថាធាតុណា ឬ ឆ្នាំណាឡើយ ។

# តារាងផ្សំសម្ពង្ស

១-ពង្សមនុស្សប្រុស និង មនុស្សស្រី ល្អប្រសើរណាស់

ប្រុសឆ្នាំឆ្លូវ និង ស្រីឆ្នាំថោះ

ប្រុសឆ្នាំម្សាញ់និង ស្រីឆ្នាំកុរ

ប្រុសឆ្នាំឆ្លូវ និង ស្រីឆ្នាំកុរ

ប្រុសឆ្នាំម្សាញ់និង ស្រីឆ្នាំថោះ

ឆ្នាំដូចខាងលើនេះ អាចរស់នៅជាមួយគ្នាបានសុខសាន្ត សំបូរទៅដោយលាភសក្ការៈផ្សេងៗ និង បានកូនចៅគួរជាទីស្រឡាញ់ ។

២-ចំណែកពង្សមនុស្សប្រុស និងពង្សមនុស្សប្រុស , ពង្សមនុស្សស្រី និង ពង្សមនុស្សស្រី ល្អជា មធ្យម ។

១-ពង្សមនុស្សប្រុស និង ទេព្តាស្រី ទំនាយទាយថាល្អបង្គួរ តែត្រូវព្រាត់ប្រាសកណ្តាលទី លុះចុង ក្រោយទើបបានជួបគ្នាវិញ ដូចព្រះសុធន និងនាងកែវមនោរា ។

ប្រុសឆ្នាំឆ្លូវ និង ស្រីឆ្នាំមមី

ប្រុសឆ្នាំម្សាញ់និង ស្រីឆ្នាំមមែ

ប្រុសឆ្នាំឆ្លូវ និង ស្រីឆ្នាំមមែ

ប្រុសឆ្នាំម្សាញ់និង ស្រីឆ្នាំមមី

២-ពង្សទេព្តាស្រី និង ទេព្តាស្រី ល្អជាមធ្យម ។

១-ពង្សមនុស្សប្រុស និងពង្សយក្សស្រី ទំនាយថា ល្អតែពីដំបូង លុះចុងក្រោយនឹងត្រូវព្រាត់គ្នា ដូចពុទ្ធិសែន និង នាងកង្រី ។

ប្រុសឆ្នាំឆ្លូវ និង ស្រីឆ្នាំខាល

ប្រុសឆ្នាំឆ្លូវ និង ស្រីឆ្នាំចរ

ប្រុសឆ្នាំម្សាញ់និង ស្រីឆ្នាំចរ

ប្រុសឆ្នាំម្សាញ់និង ស្រីឆ្នាំខាល

+ឆ្នាំទាំងបួនគូរខាងលើនេះ ពុំអាចរស់នៅជាមួយគ្នាបានឡើយ នឹងត្រូវព្រាត់គ្នាមិនខាន ។

បើពង្សទេព្តាប្រុស និងទេព្តាស្រី ទំនាយថា នៅជាមួយគ្នាបានសុខសាន្ត កើតលាភកើតទ្រព្យ ល្អ ណាស់ហោង ។

ប្រុសឆ្នាំជូត និង ស្រីឆ្នាំមមី

ប្រុសឆ្នាំជូត និង ស្រីឆ្នាំមមែ

ប្រុសឆ្នាំរោង និង ស្រីឆ្នាំមមី

ប្រុសឆ្នាំរោង និង ស្រីឆ្នាំមមែ

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com
ឆ្នាំទាំងប៉ុន្មានខាងលើនេះ ល្អណាស់ វិសេសវិសាលជាងឆ្នាំណាៗទាំងអស់ ។

បើពង្សយក្សប្រុស និងយក្សស្រី ទំនាយថា អាចនៅរួមរស់ជាមួយគ្នាបាន តែច្រើនមាត់រឹងដាក់ គ្នា ពុំសូវខ្លាចគ្នាទៅវិញទៅមក ។

ប្រុសឆ្នាំវក និង ស្រីឆ្នាំខាល

ប្រុសឆ្នាំវក និង ស្រីឆ្នាំចរ

ប្រុសឆ្នាំរការ និង ស្រីឆ្នាំខាល

ប្រុសឆ្នាំរការ និង ស្រីឆ្នាំចរ

បើពង្សយក្សប្រុស និងយក្សប្រុស នៅជាមួយគ្នាបានល្អជាបង្អួរ តែច្រើនគ្រហឹមដាក់គ្នា ។

បើពង្សទេវតាប្រុស និងយក្សស្រី ទំនាយថាមិនសូវល្អ ច្រើនប្រកែកទាស់ទែងពាក្យសំដីគ្នា មាន ចរិតមិនសូវខ្លាចគ្នាទៅវិញទៅមក ។

ប្រុសឆ្នាំជូត និង ស្រីឆ្នាំខាល

ប្រុសឆ្នាំជូត និង ស្រីឆ្នាំចរ

ប្រុសឆ្នាំរោង និង ស្រីឆ្នាំខាល

ប្រុសឆ្នាំរោង និង ស្រីឆ្នាំចរ

បើពង្សទេព្តាប្រុស និងទេព្តាប្រុស នៅជាមួយគ្នាមិនសូវល្អ ច្រើនប្រកែកគ្នាទៅវិញទៅមក ។

-បើពង្សយក្សស្រី និងយក្សស្រី ក៏នៅរួមរស់ជាមួយគ្នាមិនសូវល្អដែរ ច្រើនចាក់រុកឆ្កឹះឆ្កៀលគ្នា។

បើពង្សយក្សប្រុស និងមនុស្សស្រី ទំនាយថាបានល្អតែពីដំបូង លុះចុងក្រោយនឹងត្រូវព្រាត់គ្នា ដូចយក្សកុម្ភណ្ឌ និងនាងកែវសមន្ទា ។

ប្រុសឆ្នាំវក និង ស្រីឆ្នាំថោះ

ប្រុសឆ្នាំវក និង ស្រីឆ្នាំកុរ

ប្រុសឆ្នាំរកា និង ស្រីឆ្នាំថោះ

ប្រុសឆ្នាំរកា និង ស្រីឆ្នាំកុរ

ឆ្នាំទាំងប៉ុន្មានខាងលើនេះ ចាស់បុរាណតែងតែជៀសវាងពុំសូវផ្សំផ្គុំជាស្វាមីភរិយា ឱ្យកូនចៅ ប្រុស-ស្រីឡើយ ។

AZCambodia.com  ABCCambodia.com  AngkorDaily.com  AngkorPost.com  AngkorLink.com

បើពង្សទេព្តាប្រុស និងមនុស្សស្រី ទំនាយថារស់នៅជាមួយគ្នាបានសុខសាន្ត តែច្រើនព្រាត់គ្នា កណ្តាលទីលុះចុងក្រោយទើបបានជួបជុំគ្នាវិញ ដូចព្រះរាម និងនាង សិតា ។

ប្រុសឆ្នាំជូត   និង   ស្រីឆ្នាំថោះ

ប្រុសឆ្នាំរោង  និង   ស្រីឆ្នាំកុរ

ប្រុសឆ្នាំរោង  និង   ស្រីឆ្នាំថោះ